**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៣៣/០០៥/២០០៧

ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**សេចក្តីសម្រេច**

លេខ : ០៩៣/០០៤/២០០៧ កបធ.ច

ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ សម្រេចលុបឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន ៥៦ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងនៃឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ( ដូចមានបញ្ជីរាយនាមភ្ជាប់ជាមួយ )

- បានឃើញពាក្យបណ្តឹងរបស់លោក **អោច គឹមលាង** ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៧ ប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដែលសម្រេចលុបឈ្មោះប្រជាពលរដ្ឋចំនួន ៥៦ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង នៅការិយាល័យលេខ ០៦៥៤ ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង ០៨:៣០ នាទី
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ របស់លោក **អោច គឹមលាង** សុំដកពាក្យបណ្តឹង ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដែលប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង ១០:៣០ នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ពាក្យបណ្តឹងរបស់លោក **អោច គឹមលាង** ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ សុំដកពាក្យបណ្តឹង ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដែលប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា តាមគោលការណ៍នៃច្បាប់ ម្ចាស់បណ្តឹងមានសិទ្ធិសុំដកពាក្យបណ្តឹងរបស់ខ្លួនទាំងអស់ ឬ មួយផ្នែកបានគ្រប់ពេលវេលាទាំងអស់នៃនីតិវិធី ។

## សម្រេច

**មាត្រា ១.** ~ ទទួលពាក្យបណ្តឹងរបស់លោក **អោច គឹមលាង** ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ សុំដកពាក្យបណ្តឹង ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៧ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

**មាត្រា ២.** ~ តម្កល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដែលសម្រេចលុបឈ្មោះប្រជាពលរដ្ឋចំនួន ៥៦ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងនៅការិយាល័យលេខ ០៦៥៤ ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.** ~ សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ នាពេលប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**
**ប្រធាន**

**ឯក សំអុល**